**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩៣៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ការកំណត់ទូទៅ

## ចំពោះប្រតិបត្តិករធានារ៉ាប់រង

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការចាំបាច់នៃការងារគ្រប់គ្រង ។

## សំរេច

**ប្រការ ១.-**

អនុលោមតាមមាត្រា ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រង ប្រតិបត្តិករដែលអាចធ្វើអាជីវកម្មលើវិស័យធានារ៉ាប់រង នៅព្រះរាជាណាចក្រកម្ពុជារួមមាន ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ។

**ប្រការ ២.-**

ប្រតិបត្តិករធានារ៉ាប់រងទាំងអស់ មិនអាចធ្វើអាជីវកម្មលើវិស័យធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជាបានទេប្រសិនបើ ÷

ក/ មិនមានអាជ្ញាប័ណ្ណ និងមិនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់សំរាប់ប្រភេទធានារ៉ាប់រងណាមួយ ឬទាំងពីរប្រភេទ ។

ខ/មិនបានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវលិខិត ឬឯកសារដែលបញ្ជាក់អះអាងថាបានដាក់ប្រាក់តំកល់ចំនួនស្មើ នឹង១០(ដប់) ភាគរយនៃដើមទុនចុះបញ្ជីនៅរតនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជាទេ ។

គ/ មិនបានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវលិខិត ឬឯកសារដែលបញ្ជាក់អះអាងថាបានរក្សាទុកទឹកប្រាក់ជាគំរិតសាធនភាពមិនតិចជាង ៥០(ហាសិប) ភាគរយនៃដើមទុនចុះបញ្ជីនៅធនាគារពាណិជ្ជណាមួយ នៅព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិទេ ។

**ប្រការ ៣.-**

ក្នុងករណីដែលបុគ្គលណាម្នាក់ ឬក្រុមហ៊ុនណាមួយប្រកាសខ្លួនថាជាក្រុមហ៊ុនធានារ៉ាប់រងសំរាប់ប្រភេទធានារ៉ាប់រងណាមួយ ប៉ុន្តែតាមពិតបុគ្គល ឬក្រុមហ៊ុននោះមិនមានអាជ្ញាប័ណ្ណធានារ៉ាប់រង និងមិនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់សំរាប់ប្រភេទធានារ៉ាប់រងណាមួយទេ នោះនឹងត្រូវចោទប្រកាន់ពីបទរំលោភច្បាប់ ហើយបុគ្គល ឬក្រុមហ៊ុននោះនឹងត្រូវផ្តន្ទាទោស ដូចមានចែងនៅមាត្រា ៥៣ និងមាត្រា ៥៤នៃច្បាប់ស្តីពីការធានារ៉ាប់រង ។

**ប្រការ ៤.-**

ក្រៅពីប្រតិបត្តិករធានារ៉ាប់រង ដែលបានចុះបញ្ជីត្រឹមត្រូវ និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ចនោះ មិនអាចមានបុគ្គលណាមានសិទ្ធិប្រើប្រាស់ពាក្យ"ធានារ៉ាប់រង"ឬពាក្យណាដែលក្លាយពីពាក្យនេះ ដែលបញ្ជាក់ថាបុគ្គលនោះ ប្រកបអាជីវកម្មធានារ៉ាប់រងដោយប្រើប្រាស់ស្លាកយីហោឬសិទ្ធិប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ឬធ្វើការប្រកាសណាមួយនៅលើសេចក្តីជូនដំណឹង ឬការផ្សាយពាណិជ្ជកម្មឡើយ ។

ប្រការ ៥.

នៅពេលណាដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានហេតុផល និងភស្តុតាងគ្រប់គ្រាន់ថាក្រុមហ៊ុនណាមួយធ្វើអាជីវកម្មធានារ៉ាប់រងដោយគ្មានអាជ្ញាប័ណ្ណត្រឹមត្រូវតាមច្បាប់ នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចុះធ្វើការត្រួតពិនិត្យផ្ទាល់ដល់សាមីក្រុមហ៊ុន ដើម្បីឱ្យឃើញច្បាស់ថាក្រុមហ៊ុននោះបាន ឬ កំពុងបំពានគោលការណ៍ណាមួយនៃច្បាប់ស្តីពីការធានារ៉ាប់រង ។

ប្រការ ៦.

នៅក្នុងរយៈពេលប្រាំមួយ (៦) ខែគិតចាប់ពីថ្ងៃបានទទួលអាជ្ញាប័ណ្ណ ប្រសិនបើសាមីក្រុមហ៊ុនធានារ៉ាប់រងមិនបានធ្វើការចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់ដោយគ្មានមូលហេតុដែលអាចទទួលស្គាល់បានទេ អាជ្ញាប័ណ្ណរបស់ខ្លួននឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ ។

ប្រការ ៧.

កាលបើពិនិត្យឃើញថា ក្រុមហ៊ុនធានារ៉ាប់រងណាមួយស្ថិតនៅក្នុងស្ថានភាពមិនអាចផ្តល់ការធានាគ្រប់គ្រាន់ចំពោះកិច្ចសន្យារបស់ខ្លួន ឬមិនអាចរ៉ាប់រងបាននូវទំហំហានិភ័យ ដែលនឹងអាចកើតឡើងទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការរំលឹកដាស់តឿនជាលាយលក្ខណ៍អក្សរ និងបង្គាប់ដាច់ខាតឱ្យសាមីក្រុមហ៊ុនធានារ៉ាប់រង កសាងកម្មវិធីហិរញ្ញវត្ថុច្បាស់លាស់សំរាប់ស្តារក្រុមហ៊ុនរបស់ខ្លួនឱ្យមានប្រក្រតីភាពឡើងវិញ ។ ប្រសិនបើនៅតែគ្មានលទ្ធភាពស្តារបានតាមសេចក្តីបង្គាប់ដាច់ខាតខាងលើនេះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិហាមឃាត់ក្រុមហ៊ុនសាមីប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួន នៅព្រះរាជាណាចក្រកម្ពុជារហូតដល់មានការដោះស្រាយបានជាស្ថាពរ ។

ប្រការ ៨.

អាជ្ញាប័ណ្ណដែលត្រូវបានផ្តល់ឱ្យក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង អាចនឹងត្រូវដកហូតមកវិញបានគ្រប់ពេលវេលា កាលបើក្រុមហ៊ុនណាមួយនោះ :

-មិនអាចបំពេញគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌដែលតំរូវឱ្យអនុវត្តតាម

-មិនអាចធ្វើឱ្យបានសំរេចក្នុងរយៈពេលដែលបានយល់ព្រមចំពោះវិធានការគ្រោងទុកទាំងឡាយ តាមកម្មវិធីកែតម្រង់ឡើងវិញ

-ឬមួយមានការខ្វះខាតយ៉ាងធ្ងន់ធ្ងរក្នុងការបំពេញកាតព្វកិច្ច ដែលតម្រូវដោយបទបញ្ជាជាធរមាន ។

**ប្រការ ៩.-**

សាខាក្រុមហ៊ុនធានារ៉ាប់រងបរទេស ដែលកំពុងធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាន់ពេល នូវពតិមានសំខាន់ៗដែលពាក់ព័ន្ធដល់ការប្រែប្រួលដើមទុនសមាសភាពអ្នកចូលហ៊ុននិងធនក្ស័យនៃក្រុមហ៊ុនមេរបស់ខ្លួននៅបរទេស ។

ក្នុងករណីដែលមានការដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនធានារ៉ាប់រងមេនៅបរទេសដោយអាជ្ញាធរមានសមត្ថកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការដកហូតអាជ្ញាប័ណ្ណដែលបានចេញឱ្យសាខារបស់ក្រុមហ៊ុនមេនោះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាបន្ទាន់ភ្លាមដែរ ដើម្បីដាក់ឱ្យធ្វើការជំរះបញ្ជីបិទសាខានោះទៅតាមច្បាប់ ។

**ប្រការ ១០.-**

សេចក្តីសំរេចដកហូតអាជ្ញាប័ណ្ណជាស្ថាពរពីក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ ភ្នាក់ងារធានារ៉ាប់រងនិងជើងសាធានារ៉ាប់រង នឹងនាំទៅដល់ការរំលាយក្រុមហ៊ុននោះតាមផ្លូវច្បាប់ ។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍.។

**ប្រការ ១២.-**

ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

- ឯកសារ - កាលប្បវត្តិ